# ការបង្កើតឡើងនូវវិធីសាស្ត្របែបសហការនិងច្នៃប្រឌិត ដើម្បីអភិរក្សសម្លៀកបំពាក់ក្នុងរបបប្រល័យពូជសាសន៍

Julia M Brennan,  Caring for Textiles – Washington DC, United States

Jacquelyn Peterson-Grace, The Colonial Williamsburg Foundation – Williamsburg, VA, United States

KHO Chenda,  Tuol Sleng Genocide Museum – Phnom Penh, Cambodia

## I. សេចក្តីផ្តើម

អតីតទីតាំងធ្វើទារុណកម្មក្នុងរបបខ្មែរក្រហម ត្រូវបានគេស្គាល់ថាជាមន្ទីរ ស-21 បច្ចុប្បន្នជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (TSGM) នៅក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ បុគ្គលិកសារមន្ទីរ មើលថែទាំសមុច្ច័យសម្ភារៈដ៏មានសារៈសំខាន់ទាក់ទងទៅនឹងសម័យខ្មែរក្រហម ប៉ុន្តែវាយណភណ្ឌដែលមានលក្ខណៈជាប្រវត្តិសាស្ត្រនេះ បែរជាត្រូវបានមើលរំលងជារួមទៅវិញនៅក្នុងកំណត់ត្រាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍កម្ពុជា។ សមុច្ច័យសម្លៀកបំពាក់ រួមមានសម្លៀកបំពាក់ដែលបានពាក់ដោយអ្នកទោស និងកម្មាភិបាលខ្មែរក្រហម និងអ្នកយាម ឈ្លប និងរបស់របរផ្ទាល់ខ្លួនផ្សេងទៀត ដែលត្រូវបានរកឃើញថាមិនទាន់បានរៀបចំចងក្រងទុកជាឯកសារនៅឡើយ ហើយបានរងនូវការបំផ្លាញ។ អន្តរាគមន៍នេះ គួរណាស់តែបានធ្វើជាយូរណាស់មកហើយ។

គម្រោងដែលផ្តួចផ្តើមនៅក្នុងការអភិរក្សសម្លៀកបំពាក់ជាង 3,000 ត្រូវបានគាំទ្រដោយមូលនិធិឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកសម្រាប់ការអភិរក្សវប្បធម៌ (United States Ambassadors Fund for Cultural Preservation) នៅចន្លោះឆ្នាំ2017-2018។ គម្រោងចម្រុះនេះ ត្រូវបានបង្កើតឡើងដោយមានគោលបំណងបីសំខាន់៖ ការផ្តល់ការបណ្តុះបណ្តាលពីការការពារនិងអភិរក្សវាយណភណ្ឌទៅដល់សហការីកម្ពុជាដើម្បីជំរុញការថែទាំ ការបង្កើតឡើងនូវគោលការណ៍ចុះបញ្ជីនិងការបង្កើតបណ្ណសារវាយណភណ្ឌ និងការបង្កើតប្រព័ន្ធរក្សាទុករយៈពេលវែងប្រកបដោយចីរភាពដែលអាចបន្ថយការគំរាមកំហែងដែលកើតចេញពីអាកាសធាតុត្រូពិក។ បណ្ណសារវាយណភណ្ឌនេះ បម្រើឲ្យបេសកកម្មរបស់ TSGM ដោយបន្តការអភិរក្សនិងការស្រាវជ្រាវ និងជំរុញការផ្លាស់ប្តូរជំនាញវិជ្ជាជីវៈសម្រាប់ការសិក្សាពីការផ្សះផ្សារនិងសន្តិភាព។ គម្រោងបែបសហការនេះ ត្រូវបានផ្តួចផ្តើមបង្កើតនូវមាគ៌ាថ្មីសម្រាប់ការអនុវត្តការអភិរក្សជាបន្ត និងការបណ្តុះបណ្តាលពីការថែទាំសមុច្ច័យទាំងនេះនៅក្នុងប្រទេសកម្ពុជា។

## II. បរិបទជាប្រវត្តិសាស្ត្ររបស់ TSGM និងសមុច្ច័យវាយណភណ្ឌ

សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង គឺជាទីតាំងនិមិត្តរូបនៃការចងចាំសម្រាប់ប្រជាជនកម្ពុជា និងសហគមន៍សកលលោក។ នៅចន្លោះឆ្នាំ1975 ដល់ 1979 មានបុរស ស្ត្រី និងកុមារជាង 18,000 នាក់ បានត្រូវបានបញ្ជូនមកកាន់អតីតបរិវេណសាលាអនុវិទ្យាល័យដែលត្រូវបានគេស្គាល់ថាជាមន្ទីរសន្តិសុខ ស-21 ដែលពួកគេត្រូវប្រឈមនឹងការឃុំឃាំងធ្វើទារុណកម្ម និងសម្លាប់រង្គាល នៅក្រោមស្នាដៃខ្មែរក្រហម (រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ) (ECCC Prosecution Office, Andrew Boyle, 2019;  (Chandler, 1999)។ នៅក្នុងខែមករា ឆ្នាំ1979

ការកែប្រែទីតាំងនេះទៅជាបូជនីយដ្ឋាននៃការចងចាំ និងសារមន្ទីរ ត្រូវផ្តួចផ្តើមឡើងដោយកងកម្លាំងវៀតណាម និងកម្ពុជា (Chandler, 1999; Hawk 1981)។ TSGM ធ្វើជាសាក្សីចំពោះអំពើឃោរឃៅដែលបានប្រព្រឹត្តិឡើងនៅក្នុងបរិវេណទីតាំងរបស់ខ្លួនតាមរយៈការ អភិរក្សអគារចាស់ៗ ឧបករណ៍ធ្វើទារុណកម្ម រូបថតរបស់អ្នកទោស បណ្ណសារនៃ "ចម្លើយសារភាព" (ចម្លើយសារភាពបានមកពីការធ្វើទារុណកម្ម) (ECCC, Boyle) និងសម្លៀកបំពាក់របស់ជនរងគ្រោះ។ ដោយទទួលបានការគាំទ្រដោយកម្មវិធីការចងចាំរបស់ពិភពលោករបស់អង្គការ UNESCO (UNESCO's Memory of the World Programme) ជាផ្នែកមួយដ៏មានសារៈសំខាន់នៃកេរដំណែលរបស់កម្ពុជា សារមន្ទីរនេះជាទីតាំងកេរដំណែលវប្បធម៌មួយដែលត្រូវបានគេចូលទស្សនាច្រើនបំផុតនៅទីក្រុងភ្នំពេញ ដោយទាក់ទាញអ្នកទស្សនាជាពលរដ្ឋកម្ពុជាជាង 97,000 នាក់ និងជនបរទេសជាង 423,000 នាក់ ត្រឹមតែនៅក្នុងឆ្នាំ2018 មួយប៉ុណ្ណោះ។ (ទិន្នន័យរបស់ TSGM) **(រូបភាព 1)**



នៅដើមទសវត្សរ៍ឆ្នាំ 1980 ទួលស្លែងត្រូវបានប្រើប្រាស់ជាទីតាំងចែកចាយស្បៀង និងមនុស្សជាច្រើនបានមករកមើលមនុស្សជាទីស្រលាញ់របស់ខ្លួន ដែលបានបាត់ជីវិត តាមរយៈការមើលនៅការដាក់តាំងបង្ហាញ 'រូបថត' និងដើម្បីមកយកអង្ករ។ (រូបថតប័ណ្ណសារ TSGM)

សម្លៀកបំពាក់នៅក្នុងសមុច្ច័យវាយណភណ្ឌ ត្រូវបានប្រមូលពីក្នុងបរិវេណនិងតំបន់នៅជុំវិញនោះ ក្នុងរយៈពេលប៉ុន្មានខែ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម។ ទោះបីជាមិនដឹងច្បាស់ពីកាលប្បវត្តិទាំងស្រុងក៏ពិតមែន ប៉ុន្តែប្រភពជាចម្បងនិងភស្តុតាងដែលនិទានខ្លីៗជួយឲ្យយល់ពីប្រវត្តិនៃសមុច្ច័យនេះ។ អ្នកទោសជាធម្មតា ត្រូវបានដោះសម្លៀកបំពាក់ចេញនៅពេលមកដល់ភ្លាម ក្រោយពីពួកគេត្រូវបានថតរូបរួច។ វាយណភណ្ឌ រកបានដោយកម្រ និងមានតម្លៃណាស់ ហើយការប្រើប្រាស់ឡើងវិញ និងការកែច្នៃប្រើសម្រាប់គោលបំណងផ្សេងទៀត គឺជារឿងធម្មតាបំផុត (Yathay, 1987, Him, 2001)។ មានភស្តុតាងរស់រវើកនៃគំនរសម្លៀកបំពាក់ដែលមានធុំក្លិននៅមន្ទីរ ស-21 នៅពេលដែលកងទ័ពវៀតណាមបានមកដល់ ហើយកុមារពីរនាក់ក្នុងចំណោមកុមារប្រាំនាក់ដែលនៅមានជីវិតក្នុងមន្ទីរ ស-21 បានតំណាលប្រាប់អំពីការរួចជីវិតរបស់ពួកគេដោយសារតែការពួននៅក្នុងគំនរសម្លៀកបំពាក់ (Chandler, 1999; Phal, 2018; P. EN, personal communication 2018)។ **(រូបភាព 2)**



នង ចាន់ ផល អាយុ 8 ឆ្នាំ ប្អូនប្រុសគាត់ និងកូនបីនាក់ផ្សេងទៀត ត្រូវបានរកឃើញពួននៅក្នុងគំនរសម្លៀកបំពាក់គេបោះចោលនៅក្នុងអគារផ្ទះបាយ។ ជាកុមារម្នាក់ក្នុងចំណោមអ្នកនៅរស់រានមាន

ជីវិតពីរបីនាក់ពីមន្ទីរស-21។ គាត់បានសរសេរពីដំណើររឿងចេញពីចិត្តពិត និងលក់សៀវភៅរបស់គាត់នៅឯសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។ (រូបថតដកស្រង់ចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជា)

សម្លៀកបំពាក់ ត្រូវបានប្រើប្រាស់ដោយមេបញ្ជាការចូលកាន់តំណែងថ្មីសម្រាប់ជាមធ្យោបាយដើម្បីបង្ហាញពីទំហំនៃការប្រល័យពូជសាសន៍ជាទ្រង់ទ្រាយធំ ក្រោមរបបខ្មែរក្រហម។ រូបភាពដែលទំនងជាបានថតនៅក្នុងអំឡុងឆ្នាំ1979 ដល់ឆ្នាំ1980 បង្ហាញឲ្យឃើញពីគំនរសម្លៀកបំពាក់ដ៏ច្រើននៅក្នុងបន្ទប់រៀនមួយ ក៏ដូចជាសម្លៀកបំពាក់ដែលបាន “សម្អាត” និងរៀបចំព្យួរទុកដាក់នៅក្នុងទូកញ្ចក់មួយ (Hawk, 1981) ផងដែរ។ ចំណែកនៃការតាំងបង្ហាញរូបភាពដើម មាននៅសល់រហូតដល់សព្វថ្ងៃនេះ ដោយបានយកមកដាក់ទន្ទឹមគ្នាជាមួយនឹងរូបថតពណ៌សខ្មៅរបស់អ្នកទោសដែលបានផលិតឡើងវិញ។ **(រូបភាព 3, 4)**




គំនរសម្លៀកបំពាក់ត្រូវបានចាត់ទុកជាការតាំងបង្ហាញសម្លៀកបំពាក់លើកទីមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (TSGM) នៅដើមទសវត្សរ៍ឆ្នាំ 1980។ មកដល់ឆ្នាំ 2011 ការតាំងបង្ហាញត្រូវបានកាត់បន្ថយមកនៅត្រឹមតែពីរទូរកញ្ចក់តែប៉ុណ្ណោះ ដោយបង្ហាញពីគំនរសម្លៀកបំពាក់តិចជាងមុន និងជាសម្លៀកបំពាក់ពីរបីក្នុងប្រភេទតែមួយ។ (រូបថតពីបណ្ណសារ TSGM)

បរិបទនៅក្នុងការប្រមូលផ្តុំ និងតាំងបង្ហាញសម្លៀកបំពាក់នេះ ផ្តល់នូវការកំណត់និយមន័យយ៉ាងច្បាស់អំពីសារៈសំខាន់របស់វាចំពោះអត្តសញ្ញាណវប្បធម៌កម្ពុជា តាមការបញ្ជាក់ប្រាប់ពីខ្លឹមសារដោយអ្នករួចជីវិត និងស្ថាបនិករបស់សារមន្ទីរ និងបូជនីយដ្ឋាននៃការចងចាំនេះ។ ទោះជាយ៉ាងណា សមុច្ច័យវាយណភណ្ឌដែលនៅសេសសល់ បានប្រឈមទៅនឹងការបំផ្លាញយ៉ាងឆាប់រហ័សដោយសារផ្សិត សត្វចង្រៃ និងការគំរាមកំហែងផ្នែកជីវសាស្ត្រផ្សេងទៀត។ ប្រធានសារមន្ទីរ លោក ឆាយ វិសុទ្ធ បានផ្តល់អាទិភាពក្នុងការអភិរក្សសម្លៀកបំពាក់តាមរយៈកិច្ចសហការជាដៃគូជាមួយស្ថានទូតសហរដ្ឋអាមេរិក និងបានចាប់ផ្តើមគម្រោងដើម្បីបណ្តុះបណ្តាលដល់បុគ្គលិកសារមន្ទីរនៅក្នុងការថែទាំសមុច្ច័យនេះ។

## III. ការកំណត់ពីសារៈសំខាន់នៃសមុច្ច័យ និងការបង្កើតឡើងនូវគោលដៅអភិរក្ស

សារៈសំខាន់នៃសមុច្ច័យ ត្រូវបានកំណត់ដោយភាពជាសារវន្តរបស់វា។ គ្រឿងលម្អសម្លៀកបំពាក់ទាំងនេះ បានបន្តស្ថិតនៅដើម្បីប្រាប់ពីរឿងរ៉ាវនានារបស់ពួកខ្មែរក្រហម នៅពេលដែលមនុស្សរាប់ពាន់នាក់មិនមានជីវិតប្រាប់ពីរឿងរ៉ាវទាំងនោះបាន។ ជារួម វត្ថុទាំងនេះបង្ហាញប្រាប់រឿងរ៉ាវទូទៅរបស់មន្ទីរ ស-21 ចំណែកឯសម្លៀកបំពាក់នីមួយៗវិញ គឺតំណាងឲ្យជីវប្រវត្តិផ្ទាល់ខ្លួន។ ការអភិរក្សសម្លៀកបំពាក់ទាំងនេះ មានសារៈសំខាន់ដោយសារហេតុផលមួយចំនួនៈ ដើម្បីការគោរព និងថែរក្សារឿងរ៉ាវរបស់អ្នកដែលបានរងទុក្ខវេទនា

និងបាត់បង់ជីវិត ដើម្បីឲ្យប្រាកដថាមេរៀនដែលទទួលបានពីយុគសម័យដ៏ខ្មៅងងឹតនៃប្រវត្តិសាស្ត្រមនុស្សជាតិ មិនត្រូវបានគេបំភ្លេចចោលឡើយ និងដើម្បីផ្តល់ធនធានសម្រាប់ការស្រាវជ្រាវបន្ថែម និងការសិក្សាពីសន្តិភាព។ ដូចដែលរដ្ឋមន្ត្រីក្រសួងវប្បធម៌របស់កម្ពុជា លោក ឆេង ផុន បានលើកឡើងនៅក្នុងទសវត្សរ៍ឆ្នាំ1980 ថា៖

> យើងមានក្រពះពីរ ខាងលើសម្រាប់ដួងព្រលឹង និងខាងក្រោមសម្រាប់រាងកាយយើង។ នៅពេលក្រពះខាងលើឃ្លាន ក្រពះខាងក្រោមក៏ឃ្លានដែរ។ ដូច្នេះ ខ្មែរគ្រប់រូបត្រូវតែគិតអំពីវប្បធម៌។ ការស្តារវប្បធម៌ ត្រូវស្តារដួងព្រលឹងរបស់មនុស្សដែលត្រូវបានខូចខាតក្រោមរបប ប៉ុល ពត។ នេះគឺជាការរស់ឡើងវិញដ៏ពិតប្រាកដ (Hoskin & Hall, 1992)។

**(រូបភាព 4, 5)**






មួកដោយមានចាក់ឈ្មោះ និងអៀមរបស់ក្មេងស្រីតូចបង្ហាញជាភ័ស្តុតាងដល់មនុស្ស និងទំនាក់ទំនងមួយចំនួននៃសម្លៀកបំពាក់ត្រូវបានរកឃើញនៅឯមន្ទីរស-21។ ទាំងនេះគឺជាឧទាហរណ៍ដ៏គួរឲ្យក្តុកក្តួលនៃវប្បធម៌ជាសម្ភារៈបន្សល់ទុកជាសាក្សីនៃរបបខ្មែរក្រហម។

មុននឹងចាប់ផ្តើមការអនុវត្តការងារ គោលការណ៍ណែនាំទាំងឡាយសម្រាប់របៀបឆ្លើយតបចំពោះបញ្ហាសម្លៀកបំពាក់ ត្រូវបានកំណត់ដោយភាគីពាក់ព័ន្ធជាច្រើន រួមទាំងអ្នករួចជីវិត ប្រវត្តិវិទូ អ្នកវិទ្យាសាស្ត្រកោសល្យវិច្ច័យ ប្រធានរបស់ TSGM អ្នកអភិរក្សនៅ ‘វាលពិឃាដ’ ជើងឯក អ្នកអភិរក្សបុរាណវត្ថុ និងបញ្ញវន្តក្នុងស្រុក (Garcia-Alonso, Lacombe, 2016-2018)។ ពិធីសារគ្រប់គ្រងនេះ បានមកពីភាពចាំបាច់នៃកិច្ចដំណើរការវាយតម្លៃភ្លាមៗ និងការបញ្ជាក់ពីភាគីពាក់ព័ន្ធទាំងអស់ដែលថារាល់ការប្រាស្រ័យទាក់ទងជាមួយសមុច្ច័យ ត្រូវតែមានការណែនាំបង្ហាញដោយការគោរព។ កិច្ចដំណើរការរៀបចំសម្លៀកបំពាក់ ចាំបាច់ត្រូវរក្សាទុកឲ្យបានច្រើនតាមដែលអាចធ្វើទៅបាននូវព័ត៌មានបែបអត្ថាធិប្បាយអំពីសមាសធាតុនីមួយៗ និងសមុច្ច័យជារួម ហើយអន្តរាគមន៍ទាំងឡាយមិនគួររារាំងដល់ការចូលទៅប្រើប្រាស់នាពេលអនាគតសម្រាប់ការស្រាវជ្រាវ ឬការប្រើប្រាស់សម្រាប់ការបកស្រាយផ្សេងៗនោះទេ។ ពិធីសារថែទាំសមុច្ច័យ ចាំបាច់ត្រូវសមស្របសម្រាប់អាកាសធាតុត្រូពិក និងមាននិរន្តរភាពសម្រាប់ការអភិរក្សរយៈពេលវែង បើទោះជាស្ថិតក្នុងស្ថានភាពនៅមានកម្រិតក្តី រួមមានអគ្គិសនីមិនអាចទុកចិត្តបាន កង្វះខាតសម្ភារៈប្រើប្រាស់សម្រាប់ការអភិរក្ស និងបុគ្គលិកនៅមានកម្រិតក្នុងការអនុវត្តការងារប្រចាំថ្ងៃពាក់ព័ន្ធនឹងការគ្រប់គ្រងសមុច្ច័យ។ ការអនុវត្តការងារអភិរក្សតាមបស្ចិមប្រទេស ត្រូវបានយកមកអនុវត្តនៅក្នុងក្របខណ្ឌដែនកំណត់របស់ស្ថាប័ន និងដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃសមុច្ច័យ។

វិធីសាស្ត្រដែលបានបង្កើតឡើង គឺស្រដៀងគ្នាទៅនឹងវិធីសាស្ត្រនៃការអភិរក្សវាយណភណ្ឌវត្ថុបុរាណដូច្នោះដែរ ដែលនៅក្នុងនោះការគោរពចំពោះវត្ថុនិងបរិបទវប្បធម៌ គឺមានសារៈសំខាន់បំផុត ហើយមធ្យោបាយនៃការធ្វើអន្តរាគមន៍តិចបំផុត ច្រើនតែត្រូវបានជ្រើសរើសមកប្រើប្រាស់ដើម្បីថែរក្សាព័ត៌មានឲ្យបានច្រើនតាមដែលអាចធ្វើបាននៅក្នុងវត្ថុដែលជាប្រភពឯកសារចម្បងនេះ (Brooks, Lister, Eastop & Bennett, 1996)។ វិធាននេះក៏បានកំណត់ផងដែរថា សម្លៀកបំពាក់នីមួយៗ ត្រូវបានសម្អាតផ្ទៃខាងលើដោយប្រើប្រាស់វិធានការមេកានិកថ្នមៗតែប៉ុណ្ណោះ ដោយហេតុថា វិធានការដែលប្រើកម្លាំងខ្លាំងដូចជាការសម្អាតសើមជាដើម អាចនឹងធ្វើឲ្យបាត់បង់ព័ត៌មាននេះ។ ការចងក្រងឯកសារជាលាយលក្ខណ៍អក្សរនិងរូបភាព ផ្ដល់នូវកំណត់ត្រារបស់វត្ថុ ស្ថានភាពរបស់វា និងការពិនិត្យតាមដាន អំពីព័ត៌មានដែលវាអាចនឹងមាន។ **(រូបភាព 6,7)**





ការបង្រៀនពីរបៀបពិនិត្យទៅលើវាយនភ័ណ្ឌ និងសរសេររបាយការណ៍ពីស្ថានភាពពិត និងជាការរៀបរាប់នោះ គឺជាផ្នែកមួយដ៏មានសារៈសំខាន់នៃការបង្កើតឡើងនូវប័ណ្ណសារវាយនភ័ណ្ឌ។ វត្ថុត្រូវបានបូមធូលីយ៉ាងប្រុងប្រយ័ត្នដើម្បីយកធូលីដីចេញពីផ្ទៃ។

## IV. ការបណ្ដុះបណ្ដាលស្ដីពីការអភិរក្ស

ទីតាំងដែលត្រូវបានរៀបចំសម្រាប់ការថែទាំសមុច្ច័យនៅ TSGM គឺស្ថិតនៅក្នុងអគារមួយនៃអតីតសាលារៀន ដែលខ្មែរក្រហមបានកែប្រែអាគារនេះដើម្បីឃុំឃាំង និងធ្វើទារុណកម្មអ្នកទោស។ ការរៀបចំនេះ បានបន្ថែមនូវសមាសភាគដ៏ពិសេសទៅក្នុងកិច្ចការអភិរក្សនេះ។ ការកែប្រែទីតាំងនៃអំពើឃោរឃៅនេះទៅជាទីកន្លែងសម្រាប់ការពារវត្ថុធ្វើពីក្រណាត់ដែលតំណាងឲ្យការចងចាំរបស់បុគ្គលម្នាក់ៗ បានដើរតួជាវត្ថុគ្រើនរំលឹកប្រចាំថ្ងៃថា ការអភិរក្សគឺជាសកម្មភាពនៃការផ្សះផ្សារ ការចងចាំ និងការព្យាបាល។

ការបណ្ដុះបណ្ដាលនៅនឹងកន្លែង និងការគាំពារពីចម្ងាយសម្រាប់វគ្គបណ្ដុះបណ្ដាលរយៈពេលដប់ពីរខែ បានឆ្លុះបញ្ចាំងនូវគោលបំណងចម្បងរបស់គម្រោងរួមមាន៖ ការពង្រីកចំណេះដឹងកាន់តែមានភាពស៊ីជម្រៅស្ដីពីការអភិរក្សនិងការថែទាំសមុច្ច័យនៅក្នុងប្រទេសកម្ពុជា និងការផ្ដល់ការបណ្ដុះបណ្ដាលពីការអភិរក្សវាយណភណ្ឌដល់បុគ្គលិករបស់ TSGM។ ខូ ចិន្ដា ជាប្រធាននាយកដ្ឋានអភិរក្ស និងសិក្ខាកាមផ្នែកអភិរក្សបីរូបទៀត បានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលរយៈពេលដប់ពីរសប្ដាហ៍ ដែលរួមបញ្ចូលនូវការបង្រៀនពីការគ្រប់គ្រងសមុច្ច័យ ការគ្រប់គ្រងចម្រុះលើសត្វល្អិតចង្រៃ និងការត្រួតពិនិត្យផ្នែកបរិស្ថាន។ ការអភិរក្សការការពារ ត្រូវបានណែនាំបង្ហាញ និងសង្កេតតាមរយៈទម្រង់ការនៃភ្នាក់ងារ

បំផ្លាញទាំងដប់ប្រចាំនៅវិទ្យាស្ថានអភិរក្សកាណាដា ហើយ TSGM ត្រូវបានប្រើប្រាស់ជាករណីសិក្សា ដើម្បីបង្ហាញពីហានិភ័យ ការបំផុសគំនិត និងការអនុវត្តជម្រើសនានាដើម្បីជួយកាត់បន្ថយការខូចខាត។ ការបណ្តុះបណ្តាលបានផ្តោតទៅលើសកម្មភាពការពារដែលកំណត់ហានិភ័យនៃគ្រោះថ្នាក់ដល់វត្ថុបុរាណឲ្យនៅតិចតួច ជាជាងការធ្វើការសម្អាតដោយបង្ខំស្មុគស្មាញ ដែលអាចនឹងធ្វើឲ្យប៉ះពាល់ដល់សារៈសំខាន់នៃសម្លៀកបំពាក់សម្រាប់ជាឯកសារតឹកតាង ដោយស្ថានភាពសម្លៀកបំពាក់នោះគឺជាផ្នែកមួយនៃតម្លៃវប្បធម៌។

កម្មវិធីលម្អិតនៃការបណ្តុះបណ្តាល ត្រូវបានរៀបចំស្របទៅតាមតម្រូវការរបស់សមុច្ច័យ កម្រិតជំនាញរបស់អ្នកចូលរួម និងធនធានដែលមាននៅក្នុងស្រុក។ ជំនាញអភិរក្សវាយណភណ្ឌ ត្រូវបានចាត់ទុកជាជំនាញដ៏សំខាន់ ដោយផ្អែកទៅលើស្ថានភាពសម្លៀកបំពាក់ ហើយគោលបំណងអភិរក្សដែលបានបង្កើតឡើង ដូចជាការដេរដោយដៃ និងការសម្អាតផ្ទៃក្រណាត់ដោយប្រើប្រាសទន់និងម៉ាស៊ីនបូមធូលីជាដើម ត្រូវបានបង្រៀន បង្ហាញជាក់ស្តែង និងអនុវត្តដោយផ្ទាល់។ សមាសធាតុបណ្តុះបណ្តាលជួយដោយផ្ទាល់ដល់ការអភិវឌ្ឍនូវពិធីសារដែលយកទៅប្រើប្រាស់ដើម្បីបង្កើតបណ្ណសារវាយណភណ្ឌ។ ឧទាហរណ៍ វិធីសាស្ត្រពិនិត្យទៅលើវត្ថុនិងពាក្យបច្ចេកទេសពីរភាសាដែលបានប្រើប្រាស់ដើម្បីរៀបរាប់ស្ថានភាព បានផ្តល់ព័ត៌មានលម្អិតដល់ការចងក្រងសៀវភៅកាតាឡុក ហើយសម្លៀកបំពាក់បានមកពីសមុច្ច័យនេះ ត្រូវបានពិនិត្យតាមដានជាក្រុម ដើម្បីបង្ហាញពីពិធីសារស្ទង់មតិស្តីពីស្ថានភាពនានាសម្រាប់ការចុះបញ្ជី។ ជំនាញទាំងឡាយដែលបានបង្រៀននិងអនុវត្តនៅក្នុងសិក្ខាសាលា ត្រូវបានប្រើប្រាស់ដើម្បីរៀបចំដំណើរការសមុច្ច័យនេះពេញមួយឆ្នាំ ដោយពីដំបូងមានការបង្ហាត់បង្ហាញរបស់បុគ្គលិកបង្រៀនក្នុងសិក្ខាសាលា ហើយបន្ទាប់មកមានការផ្តល់នូវការជួយជ្រោមជ្រែងពីចម្ងាយតាមរយៈការទំនាក់ទំនងតាមអ៊ីម៉ែល និងទូរសព្ទ។

## V. ការបង្កើតបណ្ណសារវាយណភណ្ឌ TSGM

ដំណាក់កាលដំបូងនៃគម្រោង បានពិចារណាទៅលើការបណ្តុះបណ្តាលអំពីការបង្ការនិងការអភិរក្សវាយណភណ្ឌក្នុងពេលដំណាលគ្នា និងការអភិវឌ្ឍពិធីសារសម្រាប់ការចុះបញ្ជី និងការកំណត់ពីភាពចាំបាច់ត្រូវយកចិត្តទុកដាក់ចំពោះសមុច្ច័យដែលកំពុងរងការខូចខាត។ វាយណភណ្ឌតម្រូវឲ្យមានការចុះបញ្ជីពេញលេញមួយ ដើម្បីបង្កើតនូវបណ្ណសារដែលត្រូវបានកំណត់ច្បាស់លាស់ និងសម្របសម្រួលមធ្យោបាយសម្រាប់ការស្រាវជ្រាវនាពេលអនាគតនិងការបកស្រាយពីសមុច្ច័យ។ ពិធីសារចុះបញ្ជីខាងក្រោម បានដាក់បញ្ចូលនូវគោលការណ៍ដែលត្រូវបានបង្រៀន និងអនុវត្តនៅក្នុងអំឡុងពេលសិក្ខាសាលា។

1. វត្ថុនីមួយៗ ត្រូវបានកំណត់ឲ្យនូវលេខចុះបញ្ជីដោយប្រើប្រាស់ប្រព័ន្ធកំណត់ឈ្មោះជាលេខរបស់ TSGM។ វត្ថុ ត្រូវបានថតរូបដោយកាមេរ៉ាឌីជីថលដែលបានទិញដោយថវិកាមូលនិធិជំនួយ។ រូបភាព មានតួនាទីជាកំណត់ត្រារូបភាពបង្ហាញអំពីស្ថានភាពមុនពេលចាប់ផ្តើមធ្វើការសម្អាត។
2. ព័ត៌មានអំពីវត្ថុនីមួយៗ ដែលរួមបញ្ចូលនូវស្ថានភាពនិងលក្ខណៈពិសេស ដូចជាអក្សរចារឹកជាដើម ត្រូវបានកត់ត្រានៅលើច្បាប់ហាតកូពី ដែលមានជា ‘ទម្រង់វែង’។ ប្លង់ព័ត៌មានមេ មានពីរភាសា (អង់គ្លេសនិងខ្មែរ) ចំណែកឯព័ត៌មានលម្អិតពី

វត្ថុគឺជាភាសាខ្មែរ។ មូលដ្ឋានទិន្នន័យកម្មវិធី Microsoft Excel ជាអក្សរកាត់ ត្រូវបានបង្កើតឡើងដើម្បីធានាបាននូវភាពងាយស្រួលក្នុងការចូលទៅកាន់បណ្ណសារវាយណភណ្ឌ។ នៅពេលដែល TSGM ផ្លាស់ប្តូរទៅរកមូលដ្ឋានទិន្នន័យរួមក្នុងលក្ខណៈស្ថាប័នសម្រាប់វត្ថុបុរាណទាំងអស់នោះ មូលដ្ឋានទិន្នន័យឌីជីថលនេះ អាចត្រូវបានផ្ទេរចូលទៅកាន់កម្មវិធីផ្សេងទៀត។

3. វត្ថុនីមួយៗដែលច្រើនតែត្រូវបានបាំងបិទដោយគំនរធូលីក្រាស់និងមានសត្វល្អិតបង្កប់នៅក្នុងនោះ និងកម្ទេចសំណល់ជីវសាស្ត្រ ត្រូវបានសម្អាតផ្ទៃខាងលើដោយប្រើប្រាសនិងម៉ាស៊ីនបូមធូលីល្បឿនអូតូខ្លាំងឬតិចទៅតាមធូលីដែលមាន។ ធ្វើបែបនេះ ផ្តល់នូវភាពដែលអាចមើលឃើញច្បាស់ជាងមុន ហើយធូលីដែលត្រូវបានស្រូបមកនោះ ត្រូវបានរក្សាទុកសម្រាប់ការស្រាវជ្រាវនាពេលអនាគត។

4. លេខចុះបញ្ជី ត្រូវបានសរសេរនៅលើបន្ទះក្រណាត់សំឡី ហើយដេរដោយដៃនៅលើវត្ថុនីមួយៗ។ ក្រោយការសម្អាត រូបថតផ្តល់នូវការចងក្រងឯកសារស្តីពីសកម្មភាពអភិរក្ស ស្ថានភាពដែលកើតមាន និងលក្ខណៈពិសេសសំខាន់ៗ។

ដំណើរការនេះ ត្រូវបានបញ្ចប់សម្រាប់វត្ថុនីមួយៗ មានទាំងអស់ចំនួន 850 ដែលមានភាពពេញលេញគ្រប់គ្រាន់អាចមើលស្គាល់។ នៅពេលដែលការចុះបញ្ជីត្រូវបានដំណើរការនោះ វត្ថុត្រូវបានរៀបចំទុកដាក់ឡើងវិញនៅក្នុងប្រអប់ដែលមានបង់លេខ ហើយទីតាំងត្រូវបានកត់ត្រានៅក្នុងមូលដ្ឋានទិន្នន័យ ធ្វើឲ្យវត្ថុអាចទាញចេញមកវិញបាន។ ចំណែកនៃសមុច្ច័យដែលមានបំណែកក្រណាត់តូចៗនិងផ្លាស្ទិក ត្រូវបានរៀបចំចុះបញ្ជីជាក្រុមដោយប្រើប្រាស់ពិធីសារកែសម្រួល ដែលបានផ្តល់អាទិភាពដល់ការកាត់បន្ថយធូលីដី និងការពិនិត្យសព្វជ្រុងជ្រោយលើចំណែកវត្ថុនានា ដើម្បីរកឲ្យឃើញនូវវត្ថុបុរាណដ៏ពិសេសបំផុត។ ថ្វីបើមានចំណែកវត្ថុជាច្រើនមិនអាចមើលស្គាល់ក៏ពិតមែន ប៉ុន្តែវត្ថុតូចៗដូចជាច្រាសដុះធ្មេញ ក្រវិល កាបូប និងបំណែកក្រណាត់មានលក្ខណៈជាប្រវត្តិសាស្ត្រ ត្រូវបានកំណត់អត្តសញ្ញាណ។

**(រូបភាព 7, 8)**






ប្រហែលជាមួយភាគបីនៃសមុច្ច័យប័ណ្ណសារវាយនភ័ណ្ឌ គឺជាចំណែកដ៏តូចមួយ ដែលត្រូវបានរៀបចំតាមលំដាប់ ពិនិត្យមើលហើយមើលទៀត របស់របរពិសេសៗ ដូចជាគ្រឿងអលង្ការ និងការបូបតូចៗត្រូវបានយកចេញ និងក្អែលប្រឡាក់ទាំងអស់ត្រូវបានរក្សាទុកសម្រាប់ការស្រាវជ្រាវ នាពេលអនាគត។

## VI. ការរក្សាទុកបណ្ណសារវាយណភណ្ឌ TSGM

ដើម្បីសម្រេចឲ្យបាននូវគោលបំណងទីបីរបស់គម្រោង សារមន្ទីរកំពុងតែធ្វើតេស្តតាមទីតាំងជាក់ស្តែងទៅលើប្រព័ន្ធរក្សាទុកតាមមីក្រូអាកាសធាតុ (សុខុម្ពកាស) គ្រប់គ្រង

ថ្មី ដែលសម្រាលនូវផលប៉ះពាល់នៃអាកាសធាតុត្រូពិករបស់កម្ពុជា មកលើសមុច្ច័យនេះ។ ប្រព័ន្ធនេះ ត្រូវបានបង្កើតឡើងដោយអង្គការ Rhino Research Group និងមានការប្រែសម្រួលមកពីផ្នែកកសិឧស្សាហកម្ម។ វត្ថុបុរាណ ត្រូវបានដាក់ចូលទៅក្នុងប្រអប់ថ្លាប៉ូលីប្រូពីឡែន ដែលរួមបញ្ចូលនូវប្រដាប់វាស់ស្ទង់សំណើម (អ៊ីក្រូម៉ែត្រ) ដើម្បីវាស់ស្ទង់សំណើមនិងសីតុណ្ហភាពនៅខាងក្នុង។ អាលុយមីញ៉ូមស៊ីលីកាតហ្សេអូលីត ត្រូវបានគេស្គាល់ថា “អង្កាំស្ងួត” ត្រូវបានបិទភ្ជិតនៅក្នុងប្រអប់ជាមួយនឹងសម្ភារៈប្រមូលផ្តុំទាំងនោះ។ អង្កាំសេរ៉ាមិក ស្រូបយកម៉ូលេគុលទឹក ហេតុនេះនាំឲ្យមានការគ្រប់គ្រងសំណើមបានល្អនៅក្នុងប្រអប់។ អង្កាំត្រូវបានយកចេញនៅពេលកម្រិតសំណើមឡើងដល់កម្រិតកំណត់ ហើយការបើកប្រអប់ចំហ អាចជួយរក្សាលក្ខខណ្ឌខាងក្នុងតាមការចង់បាន។ សមត្ថភាពស្រូបរបស់អង្កាំ គឺងាយស្រួលបង្កើតឡើងវិញនៅក្នុងចង្ក្រានកម្ដៅដែលអាចរកទិញបាននៅក្នុងស្រុក ហើយពួកគេអាចប្រើប្រាស់ឡើងវិញដោយមិនកំណត់។

ពិធីសារនេះ ត្រូវបានធ្វើតេស្តនិងបង្កើតឡើងនៅអំឡុងពេលនៃវគ្គបណ្តុះបណ្តាលនៅនឹងកន្លែងចំនួនពីរលើក ដែលគាំទ្រដោយអ្នកជំនាញជនជាតិថៃរបស់ក្រុមអ្នកស្រាវជ្រាវ Rhino Research គឺអ្នកនាង Patcharin Taridno។ ការមកធ្វើទស្សនកិច្ចឡើងវិញដោយទីប្រឹក្សាទាំងឡាយពេញមួយឆ្នាំ បានផ្តល់នូវឱកាសនៅក្នុងការបំពេញបន្ថែមដល់ការបណ្តុះបណ្តាល និងការកែសម្រួលទៅលើពិធីសារនេះ។

**(រូបភាព 9)**



ការអានឧបករណ៍វាស់កម្រិតសំណើមពីខាងក្រៅនៃប្រអប់ ជួយឲ្យការគ្រប់គ្រងមានលក្ខណៈងាយស្រួល ដើម្បីរក្សានៅចន្លោះ 35-65% Rh សម្រាប់ប្រអប់ស្ងួតទាំង 100។

## VII. លទ្ធផលនៃគម្រោងអភិរក្សវាយណភណ្ឌ

គម្រោងនិងការប្តេជ្ញាចិត្តរបស់ក្រុមការងារអភិរក្សវាយណភណ្ឌរបស់ TSGM បានបង្កើតនូវបណ្ណសារវាយណភណ្ឌនេះឡើង។ គម្រោងក៏បានបង្កើតនូវទម្រង់គំរូមួយសម្រាប់សកម្មភាពអភិរក្សវាយណភណ្ឌ និងការស្រាវជ្រាវពីសម្លៀកបំពាក់បន្ថែមទៀតផងដែរ។ គោលការណ៍ណែនាំដែលបានបង្កើតឡើងពេញមួយរយៈពេលគម្រោង អាចយកទៅប្រើប្រាស់ចំពោះសមូហកម្មវប្បធម៌សម្ភារៈផ្សេងទៀតបាន ហើយជំនាញទាំងឡាយដែលទទួលបានដោយបុគ្គលិករបស់ TSGM នឹងត្រូវចែករំលែកបន្តទៅដល់អ្នកជំនាញផ្នែកបេតិកភណ្ឌវប្បធម៌កម្ពុជាផ្សេងទៀត ដើម្បីជួយដល់ការថែទាំបេតិកភណ្ឌវាយណភណ្ឌនៅទូទាំងប្រទេស។ គម្រោងបានផ្តល់ឱកាសសម្រាប់ការបណ្តុះបណ្តាលពហុជំនាញដល់បុគ្គលិកសារមន្ទីរ និងបានលើកកម្ពស់ទំនាក់ទំនងរវាងនាយកដ្ឋាននានារបស់ TSGM។

ការស្រាវជ្រាវនេះ ក៏បាននាំមកនូវការយកចិត្តទុកដាក់ដែលត្រូវការបំផុតចំពោះសម្លៀកបំពាក់នៅ TSGM។ អ្នកអភិរក្ស ខូ ចិន្តា បានផ្តល់នូវបទបង្ហាញយ៉ាងក្បោះក្បាយដល់

បុគ្គលិកសារមន្ទីរនិងបុគ្គលិកក្រសួងវប្បធម៌កម្ពុជា អំពីការអភិរក្សវាយណភណ្ឌ លទ្ធផលសិក្សា និងសារៈសំខាន់នៃការបណ្ដុះបណ្ដាល។ គាត់បញ្ជាក់ថា៖

> ការបណ្ដុះបណ្ដាល ពិតជាផ្ដល់ផ្លែផ្កាសម្រាប់ពួកយើងទាំងអស់គ្នា។ ខ្ញុំទទួលបាននូវចំណេះដឹងទាំងអស់ដែលខ្ញុំត្រូវការដើម្បីអភិរក្សវាយណភណ្ឌជាប្រវត្តិសាស្ត្រ ហើយខ្ញុំពេញចិត្តក្នុងការចែករំលែកចំណេះដឹងរបស់ខ្ញុំជាមួយនឹងអ្នកផ្សេងទៀត ដើម្បីឲ្យប្រាកដថាគ្មានភ័ស្តុតាងណាមួយនឹងបាត់បង់ឡើយនាពេលអនាគត។

ការចាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ បានផ្ដល់នូវមធ្យោបាយក្នុងការចែករំលែកនូវគោលគំនិតសំខាន់ៗនៃគម្រោង និងសារៈសំខាន់នៃការអភិរក្សជាមួយនឹងសហគមន៍អន្តរជាតិ។

ត្រឹមចុងឆ្នាំ2018 ក្រុមការងារអភិរក្សវាយណភណ្ឌរបស់ TSGM បានបញ្ចប់នូវការចុះបញ្ជីការសម្អាតជាមូលដ្ឋាន និងការរៀបចំទុកដាក់សមុច្ច័យទាំងមូលឡើងវិញ។ បណ្ដុំនៃរបស់របរដែលភាគច្រើនបំផុតនៅមិនទាន់ខូចខាត រួមមានខោជើងវែង អាវ មួក កាបូបស្ពាយ កាបូបដាក់របស់របរ ខ្សែក្រវ៉ាត់ និងស្បែកជើង យ៉ាងហោចណាស់មួយភាគបីនៃរបស់របរនោះ គឺមានជាប់ពាក់ព័ន្ធនឹងយោធា។ អ្វីៗដែលបានរកឃើញរួមមាន អាវខ្មៅ និងម៉ូត 'ខោអាវ' ទាហានពណ៌បៃតង ដែលជា 'ឯកសណ្ឋាន' ស្ដង់ដាសម្រាប់ខ្មែរក្រហម ព្រមជាមួយនឹងពីដុងទឹក ស្បោងយួរពណ៌បៃតង និងមួកដែលមានសញ្ញាសម្គាល់ 'ម៉ៅ' ។ សម្ភារៈទាំងនេះ គាំទ្រដល់របាយការណ៍ដែលថាអ្នកទោសត្រូវបានដោះសម្លៀកបំពាក់ចេញ ទុកតែខោខ្លីប៉ុណ្ណោះ នៅពេលគេមកដល់ និងបញ្ជាក់ពីវត្តមាន សកម្មភាពយោធា និងការឃុំឃាំងរបស់ខ្មែរក្រហមនៅមន្ទីរ ស-21 (Chandler 1999; Hawk 1981)។ ការរៀបចំបំណែកទាំងឡាយ បានបង្ហាញពីឧទាហរណ៍ដ៏មានសារៈសំខាន់មួយចំនួននៃវប្បធម៌សម្ភារៈកម្ពុជា រួមមានសារខ្លីៗសរសេរដោយដៃ គ្រឿងអលង្ការ វត្ថុធ្វើពីសូត្រ និងវាយណភណ្ឌដែលមានលក្ខណៈពិសេសជាសម្គាល់។ សម្លៀកបំពាក់ចំនួនចិតសិប និងរបស់របរបន្ទាប់បន្សំ រួមបញ្ចូលទាំងប្រភពដែលបញ្ជាក់ពីបុគ្គល ដូចជាឈ្មោះប៉ាក់ ឬទិន្នន័យយោធាជាដើម។

ដំណើរការចុះបញ្ជី ផ្ដល់នូវការយល់ដឹងកាន់តែស៊ីជម្រៅពីវត្ថុទាំងឡាយនៅក្នុងសមុច្ច័យនេះ តាមរយៈការពិនិត្យដោយប្រុងប្រយ័ត្ន និងកំណត់ត្រាលម្អិតជាលាយលក្ខណ៍អក្សរ និងកំណត់ត្រាជារូបភាព។ ឈ្មោះរកឃើញនៅលើសម្លៀកបំពាក់ អាចត្រូវបានប្រើដើម្បីពិគ្រោះផ្ទៀងផ្ទាត់ជាមួយនឹងចម្លើយសារភាព ចំនួនអ្នកទោស និងរូបថត និងសក្ខីកម្មសាលាក្ដីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC)។ ការរកឃើញទាំងនេះ ពិតជាមានសារៈសំខាន់ណាស់ ហើយសក្ដានុពលសម្រាប់ការស្រាវជ្រាវនាពេលអនាគត បញ្ជាក់ពីសារៈសំខាន់នៃសម្លៀកបំពាក់នេះថាជាផ្នែកមួយនៃបណ្ណសារទាំងមូលរបស់ TSGM។

ផែនការអនាគតសម្រាប់បណ្ណសារវាយណភណ្ឌ រួមបញ្ចូលនូវការធ្វើឲ្យប្រសើរឡើងចំពោះវត្ថុតាំងបង្ហាញ ដើម្បីពង្រីកការចេញចូលជាសាធារណៈ និងធ្វើការរៀបរាប់ឲ្យកាន់តែស៊ីជម្រៅអំពីសម័យខ្មែរក្រហម។ មូលនិធិបន្ថែម កំពុងតែស្វះស្វែងរកដើម្បីបង្កើននូវការដាក់តាំងបង្ហាញសម្លៀកបំពាក់នេះ។ ដំណាក់កាលបន្ទាប់ នឹងផ្ដោតទៅលើការអភិរក្សសម្លៀកបំពាក់ដែលមិនទាន់ត្រូវបានចងក្រងជាឯកសារនៅឡើយ ដែលសម្លៀក

បំពាក់នេះត្រូវបានដាក់តាំងបង្ហាញជាច្រើនទសវត្សរ៍មកហើយ ហើយនឹងផ្តល់នូវការបណ្តុះបណ្តាលលើការអភិរក្សបន្ថែមទៀត។ បន្ថែមលើនេះទៀត ប្រព័ន្ធរក្សាទុកតាមមីក្រូអាកាសធាតុ អាចនឹងត្រូវប្រើប្រាស់សម្រាប់ការរក្សាទុកឲ្យបានយូរនូវសម្ភារៈទាំងឡាយផ្សេងទៀតនៅក្នុងសមុច្ច័យរបស់ TSGM ដូចជាវត្ថុធ្វើពីលោហៈជាដើម ដែលរងការខូចខាតពីការច្រែះចាប់។ **(រូបភាព 10, 11, 12)**





ដំណើរវិកចម្រើននៃស្ថានភាពការរក្សាទុកដាក់សមុច្ច័យចាប់ពីមុនឆ្នាំ 2015 (ដាក់ក្នុងស្បោងសម្រាម) មកជាកេសផ្លាស្ទិកបើកចំហរ និងទីបំផុតមកជាបន្ទប់ទុកដាក់នៅក្នុងឆ្នាំ 2019 ដោយមានទូរតម្កល់ និងប្រអប់ស្លួតត្រឹមត្រូវ។

## VII. សេចក្តីសន្និដ្ឋាន

តាមលក្ខណៈសម្គាល់ជាធម្មតារបស់វា សម្លៀកបំពាក់បង្ហាញយ៉ាងច្បាស់មិនអាចប្រកែកបានទៅដល់យុវជនកម្ពុជាអំពីសេចក្តីលម្អិតនៃវប្បធម៌ ក្នុងពេលដំណាលគ្នានោះដែរ វាក៏ផ្តល់ផងដែរនូវតឹកតាងសម្រាប់អ្នកដែលបានរួចជីវិតពីយុគសម័យដ៏ខ្មៅងងឹតនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ពេញមួយរយៈពេលនៃគម្រោងនេះ សមុច្ច័យដែលមិនទាន់បានចងក្រងជាឯកសារពីមុនមក ត្រូវបានចុះបញ្ជី ថតរូប បញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យដែលអាចស្វែងរកបាន ផ្ទៃសាច់ក្រណាត់ត្រូវបានសម្អាត និងរក្សាទុកនៅក្នុងប្រព័ន្ធគ្រប់គ្រងអាកាសធាតុប្រកបដោយនិរន្តរភាពនិងនវានុវត្តភាព។ ការស្រាវជ្រាវផ្តោតលើសម្លៀកបំពាក់នេះ បូករួមជាមួយនឹងទិន្នន័យគម្រោងអភិរក្សនិងការចុះបញ្ជីនោះ ផ្តល់នូវការឆ្លុះបញ្ចាំងដ៏មានសារៈសំខាន់មួយចំនួន។

ទីមួយ នៅពេលនេះ មានរូបភាពកាន់តែច្បាស់ជាងមុនពីអ្នកដែលបានបាត់បង់ជីវិតនៅក្នុងមន្ទីរ ស-21។ សំណល់វាយណភណ្ឌដែលបានអភិរក្ស នឹងជំរុញនូវការសន្ទនាតាមបែបថ្មីជាមួយនឹងអ្នកចូលទស្សនា ជាពិសេសប្រជាជនកម្ពុជាដែលមកទស្សនា TSGM ដើម្បីបកស្រាយចម្ងល់ពាក់ព័ន្ធនឹងមនុស្សជាទីស្រឡាញ់ ផ្សះផ្សារឿងរ៉ាវអតីតកាល និងបន្តចលនាឆ្ពោះទៅរកសន្តិភាព។

ទីពីរ ការបណ្តុះបណ្តាលនិងកិច្ចខិតខំប្រឹងប្រែងសហការ បានលើកកម្ពស់នូវសារៈសំខាន់នៃសមុច្ច័យសម្លៀកបំពាក់នេះ ហើយម្យ៉ាងទៀត លើកកម្ពស់នូវមរតកវាយណភណ្ឌកម្ពុជាសម្រាប់ទាំងគ្រូឧទ្ទេសនិងសិក្ខាកាម និងសម្រាប់សាធារណជនជារួមផងដែរ។ ការបណ្តុះ

បណ្តាលពីការអភិរក្ស បានភ្ជាប់ទំនាក់ទំនងជាមួយនឹងភាគីពាក់ព័ន្ធ និងបានប្រកាន់យកនូវការគោរពចំពោះវប្បធម៌សម្ភារៈរូបិយ ព្រមជាមួយគ្នានោះដែរ ក៏បានលើកកម្ពស់ការអនុវត្តប្រកបដោយចីរភាពផងដែរ។ គម្រោងបានប្រើប្រាស់វិធីសាស្រ្តអភិរក្សតាមបែបបស្ចិមលោក និងការអនុវត្តបែបបុរាណវត្ថុវិទ្យា ដើម្បីឆ្លើយតបចំពោះមរតកវប្បធម៌កម្ពុជា លទ្ធភាពមានកម្រិតរបស់ស្ថាប័ន និងផលលំបាកទាំងឡាយដែលបានកើតឡើងដោយស្ថានភាពធ្ងន់ធ្ងរនៃសមុច្ច័យនេះ។

ទីបី ពិធីសារសម្អាតដែលបានលើកឡើងនេះ គឺមានលក្ខណៈពិសេសប្លែកដើម្បីអភិរក្សវាយណភណ្ឌសម័យប្រល័យពូជសាសន៍ដែលកំពុងខូចខាត ដែលសម្លៀកបំពាក់ទាំងនោះផ្ទាល់ តំណាងឲ្យជនរងគ្រោះរាប់ពាន់នាក់នៃរបបប្រល័យពូជសាសន៍ និងអ្នកដែលបានប្រព្រឹត្តិអំពើប្រល័យពូជសាសន៍។ ស្នាមប្រឡាក់និងធូលីដី ត្រូវបានចាត់ទុកថាជាផ្នែកមួយនៃប្រភពដើមនិងគុណតម្លៃជាភស្តុតាងនៃវាយណភណ្ឌ។ ការកំណត់ដាក់លាក់ទៅលើកម្រិតនៃការសម្អាត និងរបៀបក្នុងការរក្សាស្ថិរភាព ត្រូវបានបង្កើតឡើងតាមកិច្ចសហការជាមួយក្រុមការងារ TGSM និងអ្នកជំនាញវិជ្ជាជីវៈផ្នែកបេតិកភណ្ឌផ្សេងទៀត។

គម្រោងនេះ បង្ហាញជាគំរូពីសារៈសំខាន់នៃការអភិរក្ស ជាពិសេសសម្រាប់សម្ភារៈសរីរាង្គមានដែលងាយរងការបំផ្លាញដោយអាកាសធាតុប្រែប្រួលខ្លាំង។ សម្លៀកបំពាក់ទាំងនេះ និងកំណត់ត្រាជីវប្រវត្តិទាំងឡាយដែលមានជានិមិត្តរូបលើសម្លៀកបំពាក់នេះ កំពុងត្រូវបានការផ្តល់តម្លៃ យកមកសិក្សាស្រាវជ្រាវ និងទទួលបានការយកចិត្តទុកដាក់។ អ្នកអភិរក្ស ខូ ចិន្តា បានលើកឡើងពីសារៈសំខាន់នៃការអភិរក្ស និងទំនាក់ទំនងរបស់វាទៅនឹងបេសកកម្មរបស់សារមន្ទីរ ដើម្បីអប់រំអំពីប្រវត្តិសាស្រ្តដ៏គួរឲ្យរន្ធត់នៃរបបខ្មែរក្រហមនៅក្នុងអត្ថបទរបស់អាសូស៊ីអេតធិត ប្រេស (Associated Press) ឆ្នាំ2018៖

> ប្រសិនបើសម្លៀកបំពាក់នោះចាស់ពេក និងពុកផុយនោះ ពេលនោះភស្តុតាងដែលវាផ្តល់ឲ្យ នឹងត្រូវបាត់បង់ទៅ ហើយនៅពេលអ្នកនិយាយទៅកាន់ក្មេងជំនាន់ក្រោយៗ ពួកគេនឹងមិនជឿអ្នកទេ។

**(រូបភាព 13, 14)**



ធ្វើការពន្យល់ពីគោលការណ៍នៃការអភិរក្សវាយនភ័ណ្ឌ និងបច្ចេកវិទ្យា Drybead ចំពោះអ្នកជំនាញផ្នែកបេតិកភណ្ឌមកបម្រើការក្នុងរយៈពេលខ្លី និងអ្នកផ្តល់មូលនិធិ និងនៅឯពិព័រណ៍ វិទ្យាសាស្រ្ត បច្ចេកវិទ្យា វិស្វកម្ម គណិវិទ្យា (STEM) នៅក្នុងទីក្រុងភ្នំពេញ ជួយលើកកម្ពស់ដល់កិត្យានុភាពគម្រោង និងជម្រុញការយល់ដឹងកាន់តែខ្លាំងឡើងពីប្រវត្តិសាស្រ្តដ៏សំខាន់មួយនេះ។



ជើងថា “តើអ្វីជាសារៈសំខាន់នៃការអភិរក្ស” ដោយក្រុមប្រឹក្សាអន្តរជាតិនៃសារមន្ទីរ (ICOM) និងគណៈកម្មាធិការអន្តរជាតិសម្រាប់វិទ្យាសាស្ត្រស្តីពីការរៀបចំសារមន្ទីរ (ICOFOM) នៅ ICOM ទីក្រុងក្យូតុ ឆ្នាំ2019 នៅក្នុងអង្គសន្និបាតទី25។


## សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះជំនួយ និងការគាំទ្ររបស់៖

- លោក ឆាយ វិសុទ្ធ លោក ឈាង សុខពេញ លោក ញាណ ចិត្រី នៃសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង
- ឯកឧត្តម ប្រាក់ សុណ្ណារ៉ា នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- អ្នកស្រី អារ៉េន ស្វាតជេស លីនណេត ឌី ហ្វ្រង់កូ (Arendt Zwartjes, Linnette D. Franco) អ្នកស្រី នន សុរីមាស នៃស្ថានទូតអាមេរិកប្រចាំទីក្រុងភ្នំពេញ
- អ្នកស្រី បាកបារ៉ា ធីម (Barbara Thimm) អ្នកស្រី យូលី ម៉ាតថេ (Julie Matthées) និង អ្នកស្រី ហេលេណា ហ៊ូសស្មាន់ (Hellena Huesmann) មកពីទីភ្នាក់ងារអភិវឌ្ឍន៍ Deutsche Gesellschaft für Internationale Zusammenarbeit (GIZ)
- បណ្ឌិត យ៉ូហាន វ៉ាន អាសប្រ៊ូក (Johan Van Asbrouck) និង អ្នកនាង ប៉ាតចារីន តារីតណូ (Patcharin Taridno) នៃក្រុមស្រាវជ្រាវ .Rhino Research Ltd
- លោក ជា សុភាព នៃមជ្ឈមណ្ឌល បុប្ផាណា
- បណ្ឌិត យូលី ហ្វ្លីស្ស៍ម៉ាន (Julie Fleischman) អ្នកស្រី ម៉ាកតា ស្វីតុន (Marta Swieton) អ្នកស្រី អេវ៉េល លីណា ប៊ីសាហ្គា (Ewelina Bisaga) អ្នកស្រី អេលីហ្សាបេត បេកឃើ (Elizabeth Becker) អ្នកស្រី អេនជែល ប្រេសស្ត្រុប (Angel Braestrup) និងអ្នកស្រី មីស្សែល ឃូពើ (Michele Cooper)

សម្រាប់ការផ្តល់នូវជំនាញឯកទេសរបស់លោក-លោកស្រី។


## ឯកសារពិគ្រោះ


Becker, E. (2010). *Bophana, Love in the Time of the Khmer Rouge*, Cambodia Daily Press.

Brooks, M., Lister, A., Eastop, D., Bennett, T. (1996). Artifact of Information? Articulating the Conflicts in Conserving Archaeological Textiles. *International Institute for Conservation: Archaeological Conservation and Its Consequences, Preprints of the Contributions to the Copenhagen Congress*. 16-21.

Chandler, D.P. (1999). *Voices from S-21, Terror and History in Pol Pot’s Secret Prison.* Thailand: Silkworm Books.

Chea, N., Chea S., Sonine K., and Chanmara, P. (2003). *Seams of Change: Clothing and the Care of the Self in late 19th and 20th century Cambodia (*Phnom Penh: Reyum Publishing.

Hawk, D. (1981). “*Cambodia: A Report from Phnom Penh*”, New Republic, 15 November, 1981.

Him, C. (2001). *When Broken Glass Floats: Growing Up Under the Khmer Rouge: A Memoir*. New York: W.W. Norton.

Hoskin, J. & Hall, T. (1992). *Cambodia, a Portrait.* Bangkok: Asia Books.

Panh, R. (2003). "S21: The Khmer Rouge Killing Machine". Arte France Cinéma, Institut National de l'Audiovisuel (INA) (film)

Phal, N. C. (2018). *The Mystery of the Boy at S-21: A Story of Family, Love, and the Struggle to Rebuild Life after the Khmer Rouge Genocide*. Phnom Penh: Cambodian Institute for Peace and Development.

Ponchaud, F. (1978). *Cambodia Year Zero*. New York: Holt, Rinehart & Winston.

Yathay, P. (1987). *Stay Alive My Son*. Thailand: Silkworm Books.